AMBASSADE DE FRANCE
AU
CAMBODGE

*Service de Presse*

## COMMMUNIQUE DE PRESSE

Son Excellence Monsieur UNG Huot, Ministre des Affaires Etrangères et de la Coopération Internationale, et Son Excellence Monsieur Gildas Le LIDEC, Ambassadeur de France, ont signé au Ministère des Affaires étrangères et de la Coopération internationale la quatrième convention de financement pour la constitution du complexe hospitalo-universitaire Calmette.

Cette convention d'un montant de 15 millions de francs français (soit environ 7,5 milliards de riels ou 3 millions de dollars) servira à poursuivre le financement du renforcement des capacités nationales de formation des personnels médicaux et paramédicaux (en formation initiale et en formation continue) et la rénovation des infrastructures et des équipements de l'hôpital Calmette pour améliorer la qualité des soins.

Avec le don d'aujourd'hui, c'est 22,5 milliards de riels (45,3 millions de francs français ou 9 millions de dollars) qu'aura reçu le complexe hospitalo-universitaire Calmette depuis l'année 1993, date de naissance du projet.

A ce financement s'ajoute la rémunération de quinze experts français : un professeur de médecine, conseiller du Doyen de la faculté de médecine, de pharmacie et d'odontostomatologie, deux médecins et un gestionnaire à l'Institut Pasteur du Cambodge et, à l'hôpital Calmette, quatre médecins, un pharmacien biologiste, quatre cadres infirmiers et deux cadres administratifs.

L'ensemble hospitalo-universitaire Calmette est constitué de l'Institut Pasteur du Cambodge qui est ouvert depuis le début de l'année 1995, de la faculté mixte et de l'hôpital Calmette dont la rénovation est en cours et sera terminée fin 1997 - début 1998./.

Phnom-Penh, le 23 décembre 1996.

AMBASSADE DE FRANCE AU CAMBODGE
REPUBLIQUE FRANCAISE

ស្ថានទូតបារាំងប្រចាំព្រះរាជាណាចក្រកម្ពុជា

❖ ❖

ការិយាល័យពត៌មាន

❖

# សេចក្តីជូនដំណឹង

នាថ្ងៃទី២៣ខែធ្នូឆ្នាំ១៩៩៦នេះ នៅទីស្តីការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ឯកឧត្តម **អ៊ឹង ហួត** រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ព្រមទាំងឯកឧត្តម **ហ្ស៊ីលដាស់ លើ លីដេច** ឯកអគ្គរដ្ឋទូតបារាំងប្រចាំព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចុះហត្ថលេខាលើអនុសញ្ញាហិរញ្ញវត្ថុលើកទី៤ ស្តីពីការផ្តល់ជំនួយរបស់បារាំងដល់ការរៀបចំនិងកសាងនូវមជ្ឈមណ្ឌលសុខាភិបាល_សាកលវិទ្យាល័យកាលម៉ែត ។

ជំនួយរបស់បារាំងខាងលើនេះដែលមានទឹកប្រាក់ចំនួន១៥លានហ្វ្រង់(ស្មើនឹង៣លានដុល្លារស.រ.អា) នឹងត្រូវប្រើប្រាស់ដើម្បីដំណើរការតទៅមុខទៀតព្រមទាំងពង្រឹងនូវលទ្ធភាពរបស់ប្រទេសកម្ពុជាក្នុងការបណ្តុះបណ្តាលជាដំបូងឬជាបន្តនូវមន្ត្រីពេទ្យ អ្នកជំនួយការនិងបុគ្គលិកសុខាភិបាល ។ ទន្ទឹមនឹងនេះ ជំនួយរបស់បារាំងនេះក៏នឹងត្រូវប្រើប្រាស់សំរាប់កែលំអរហេដ្ឋារចនាសម្ព័ន្ធ និងសំរាប់បំពាក់បរិក្ខារដល់មន្ទីរពេទ្យកាល់ម៉ែតផងដែរ ។ កិច្ចសហប្រតិបត្តិការរបស់បារាំងខាងលើនេះបានធ្វើឡើងក្នុងបំណងចង់ឱ្យការព្យាបាលនិងថែរក្សាអ្នកជំងឺមានភាពប្រសើរឡើងវិញ ។

តាំងពីគំរោងរៀបចំបង្កើតមជ្ឈមណ្ឌលសុខាភិបាល_សាកលវិទ្យាល័យកាលម៉ែត បានចេញជារូបរៀងមកនៅឆ្នាំ១៩៩៣ ប្រទេសបារាំងបានផ្តល់ជំនួយចំនួន៤៥លាន៣សែនហ្វ្រង់ (ស្មើនឹង៩លានដុល្លារស.រ.អា) សំរាប់គំរោងនេះដោយគិតទាំងជំនួយដែលបារាំងបានផ្តល់នៅថ្ងៃនេះផងដែរ ។

បន្ថែមលើហិរញ្ញប្បទាននេះ បារាំងក៏បានបន្តការផ្តល់ប្រាក់បៀវត្ស៍ ដល់អ្នកឯកទេសបារាំងចំនួន១៥នាក់ទៀតដែរ ។ អ្នកឯកទេសបារាំងចំនួន១៥នាក់នេះមាន : វេជ្ជសាស្ត្រាចារ្យម្នាក់ជាទីប្រឹក្សាលោកព្រឹទ្ធសាស្ត្រាចារ្យនៃមហាវិទ្យាល័យវេជ្ជសាស្ត្រ_ឱសថសាស្ត្រនិងទន្តសាស្ត្រ វេជ្ជបណ្ឌិត២នាក់និងអ្នកគ្រប់គ្រងហិរញ្ញវត្ថុម្នាក់ប្រចាំនៅវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ព្រមទាំងវេជ្ជបណ្ឌិត៨នាក់ ឱសថការី_ជីវសាស្ត្រម្នាក់ មន្ត្រីគិលានុបដ្ឋាក២នាក់ និងមន្ត្រីរដ្ឋបាល២នាក់ទៀតប្រចាំនៅមន្ទីរពេទ្យកាល់ម៉ែត ។

គួររម្លឹកផងដែរថា មជ្ឈមណ្ឌលសុខាភិបាល_សាកលវិទ្យាល័យកាលម៉ែតជាគ្រឹះស្ថានមួយ ដែលមានរួមបញ្ចូល : វិទ្យាស្ថានប៉ាស្ទ័រកម្ពុជាដែលបានបើកទ្វារកាលពីដើមឆ្នាំ១៩៩៥ មហាវិទ្យាល័យវេជ្ជសាស្ត្រ_ឱសថសាស្ត្រនិងទន្តសាស្ត្រ និងមន្ទីរពេទ្យកាល់ម៉ែត ដែលរាល់កិច្ចការដើម្បីកែលំអនិងរៀបចំឡើងវិញនូវមន្ទីរពេទ្យនេះកំពុងតែធ្វើជាបន្ត ហើយនិងត្រូវបញ្ចប់សព្វគ្រប់នៅអំឡុងចុងឆ្នាំ១៩៩៧ឬយ៉ាងយូរនាដើមឆ្នាំ១៩៩៨ខាងមុខនេះ ៕

ភ្នំពេញ.ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៩៦

